# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ លោកបណ្ឌិត ឡៅ-ម៉ុងហៃ ពោលថា
## ឈប់គិតគូររឿងកោះត្រល់ និងកម្ពុជាក្រោម ។

www.hoksavann.org

ថ្ងៃទី៣ ធ្នូ ២០១២



«កម្ពុជាគួរគិតពីបញ្ហាអភិវឌ្ឍន៍ប្រទេស ប្រសើរជាងបញ្ហាជម្លោះព្រំដែន ឈប់គិតគូររឿងកោះត្រល់និងកម្ពុជាក្រោម ជារឿងចប់ហើយ», នេះជាសំដីលោកបណ្ឌិតឡៅ-ម៉ុងហៃ ពោ-លឡើងកាលបពីថ្ងៃ២ តុលា ២០១២ តាមរយៈវិទ្យុអាស៊ីសេរី ។

ទស្សនៈនេះរបស់លោកមានការប្រឆាំងយ៉ាងខ្លាំង ពីមជ្ឈដ្ឋានអ្នកស្តាប់ខ្លះ រហូតចោទលោកថា ជាជនក្បត់ជាតិ ។ ដោយមានប្រតិកម្មយ៉ាងខ្លាំងនេះហើយ ទើបវិទ្យុអាស៊ីសេរីបានបើកវេទិកាអ្នកស្តាប់ កាលពីថ្ងៃ៧ ធ្នូ ២០១២ ដើម្បីសុំឲ្យលោកបញ្ជាក់បន្ថែម ។ ក្នុងចម្លើយទៅកាន់អ្នកសម្របសម្រួលនៃវេទិកាអ្នកស្តាប់ លោកបណ្ឌិតឆ្លើយពុំបានច្បាស់លាស់ឡើយ មានចម្លើយខ្លះខុសនឹងសំនួរផង ដែលធ្វើឲ្យអ្នកស្តាប់យល់ថា លោកឡៅ-ម៉ុងហៃមានការស្តាយក្រោយ ដោយសំដីរបស់លោកមានការឆ្គាំឆ្គងបង្អាក់ដំណើរអ្នកស្នេហាជាតិ ។

យើងក៏ចាប់អារម្មណ៍យ៉ាងខ្លាំងណាស់ដែរ ចំពោះទស្សនៈរបស់លោកឡៅ-ម៉ុងហៃ ប៉ុន្តែជាប់រវល់ធ្វើវិភាគបញ្ហាសិទ្ធិមនុស្ស ។ ពេលនេះយើងសូមបញ្ចេញទស្សនៈរបស់យើង ដោយផ្អែកលើឧត្តមគតិរបស់ ព្រះពុទ្ធសាសនាផង តើគួរឲ្យជនជាតិខ្មែរឈប់គិតគូរអំពីកម្ពុជាក្រោមនិងកោះត្រល់ តាមទស្សនៈរបស់លោកបណ្ឌិតឡៅ-ម៉ុងហៃឬទេ ? ។

ក្នុងមាតិកាទី២នៃប្រយោជន៍បច្ចុប្បន្ន៤យ៉ាងរបស់ព្រះពុទ្ធសាសនា ព្រះពុទ្ធជាម្ចាស់ពោលថា អារក្ខសម្បទា ត្រូវថែរក្សារបស់ដែលមាន ត្រូវស្វែងរករបស់ដែលបាត់បង់ ។ យ៉ាងណាមិញ ទឹកដីកម្ពុជាក្រោមជាទឹកដីរបស់ខ្មែរ ត្រូវបារាំងកាត់ឲ្យវៀតណាមនៅឆ្នាំ១៩៤៩ ។ ក្រោមអាណានិគមនិយមវៀតណាម ខ្មែរកម្ពុជាក្រោមបានទទួលរងទុក្ខវេទនាយ៉ាងខ្លាំងក្លា ដោ-យកុម្មុយនិស្តវៀតណាមធ្វើទុក្ខបុកម្នេញ ព្រះសង្ឃនិងពុទ្ធបរិស័ទខ្មែរ មានធ្វើគត សម្លាប់ ចាប់ផ្សឹកព្រះសង្ឃ និងចោទដាក់ពន្ធនាគារជាដើម ។ គាបសង្កត់ផ្នែកវប្បធម៌ មិនឲ្យរៀនអក្សរខ្មែរ កម្រិតក្នុងការគោរពព្រះពុទ្ធសាសនា ។ ខ្មែរកម្ពុជាក្រោមខ្លះទ្រាំទ្រនឹងការគាបសង្កត់មិនបាន ក៏រត់មករស់នៅក្នុងប្រទេសកម្ពុជា តែត្រូវអាជ្ញាធរខ្មែរកម្ពុជាកណ្តាលគាបសង្កត់មួយជាន់ទៀត ដោយពុំអើពើដោះស្រាយជីវភាពរស់នៅរបស់ខ្មែរកម្ពុជាក្រោមទាំងនោះឡើយ ដូចជាពុំព្រមផ្តល់ជូននូវសញ្ជាតិជាដើ-ម គេប្រាប់ថា គេអាចឲ្យសញ្ជាតិ លុះត្រាតែលុបកំណើតនៅកម្ពុជាក្រោម ។ ព្រះភិក្ខុទឹម-សាខនត្រូវអាជ្ញាធរខ្មែរចាប់ផ្សឹក រួចបញ្ជូនទៅឲ្យវៀតណាមកាត់ទោស ។ ព្រះសង្ឃខ្មែរកម្ពុជាក្រោមមួយអង្គត្រូវគេធ្វើគតក្នុងវត្តនៅភ្នំពេញដោយអាថ៌កំបាំង ។ ព្រះសង្ឃខ្មែរកម្ពុជាក្រោមមួយក្រុមត្រូវអាជ្ញាធរខ្មែរវាយធ្វើបាប ក្នុងឱកាសយកញត្តិទៅឲ្យទូតយួននៅភ្នំពេញ ដើម្បីសុំឲ្យវៀតណាមឈប់គាបសង្កត់ព្រះសង្ឃនិងខ្មែរកម្ពុជាក្រោម ។ល។

ដោយឃើញទិដ្ឋភាពដ៏ខ្លោចផ្សា ចុះទឹកក្រពើឡើងលើខ្លាបែបនេះ បងប្អូនខ្មែរកម្ពុជាក្រោមត្រូវតែងើបឡើងតស៊ូ ខ្លួនទីពឹងខ្លួន ទើបសហព័ន្ធខ្មែរកម្ពុជាក្រោមបានបង្កើតឡើង ដើម្បីទាមទារសិទ្ធិរបស់ខ្លួនជាម្ចាស់ទឹកដីតាមច្បាប់អង្គការសហប្រជា-ជាតិ ។ សកម្មភាពនេះ ទោះបីមិនទាន់បានសំរេចជាឯករាជ្យ ឬជាស្វយ័តក៏ដោយ ក៏អំពើគាបសង្កត់របស់រដ្ឋាភិបាលវៀតណាមមកលើខ្មែរកម្ពុជាក្រោមបានធូរស្រាលខ្លះដែរ ដោយការព្រមានពីអង្គការសហប្រជាជាតិ អំពីការរំលោភសិទ្ធិមនុស្សរបស់រដ្ឋាភិបាលនៃប្រទេសវៀតណាមនេះ ។

ត្រង់ឧត្តមគតិរើបំរះក្រោកឡើងតស៊ូនេះរបស់បងប្អូនខ្មែរកម្ពុជាក្រោម ជាឧត្តមគតិដ៏ត្រឹមត្រូវ គួរកោតសរសើរខ្លាំងណាស់ ។ ឧត្តមគតិនិងសកម្មភាពនេះ ជាចម្លើយឆ្លើយតបទៅនឹងទស្សនៈរបស់លោកបណ្ឌិតឡៅ-ម៉ុងហៃបានហើយ ថាបងប្អូនខ្មែរកម្ពុជាក្រោមមិនអាចឱបដៃ ឲ្យវៀតណាមដកហូតសិទ្ធិរបស់ខ្លួនដោយខ្លួនមិនបានតស៊ូឡើយ ។ ការតស៊ូដ៏ត្រឹមត្រូវនេះ ក៏មិនអាចបំបាក់ស្មារតីខ្មែរកម្ពុជាកណ្តាល មិនឲ្យគាំទ្របានឡើយ ។ មួយទៀត គ្មានច្បាប់អន្តរជាតិណាមួយកាត់សេចក្តីថា ទឹកដីកម្ពុជាក្រោមដែលបារាំងប្រគល់ទៅឲ្យវៀតណាម បិទផ្លូវតវ៉ាឡើយ ។ ខ្មែរអ្នកស្នេហាជាតិមិនអាចប្រគល់ទឹកដី ឲ្យប្រទេសជិតខាងដើម្បីមិត្តភាព កុំឲ្យមានអរិភាពនឹងគ្នាឡើយ ហើយក៏មិនអាចធ្វើការអភិវឌ្ឍន៍ ត្រូវលះបង់ការទាមទារទឹកដីដូចទស្សនៈបណ្ឌិតឡៅ-ម៉ុងហៃឡើយ ។

អំពីកោះត្រល់ ក៏មានន័យដូចខាងលើនេះដែរ ។ នៅឆ្នាំ១៩៣៩ លោក Brévié មិនបានប្រគល់កោះនេះទៅឲ្យវៀតណាមឡើយ គ្រាន់តែបារាំងអាណានិគមនិយមចែកជាតំបន់ត្រួតត្រាប៉ុណ្ណោះ ។ ទោះបីឆ្នាំ១៩៦៤ ដែលព្រះប្រមុខរដ្ឋសម្តេចនរោត្តម-សីហនុយកផែនទីនៃប្រទេសកម្ពុជា ទៅតម្កល់នៅអង្គការសហប្រជាជាតិ ក៏ពុំមានបានន័យថា ឈប់ទាមទារសិទ្ធិលើកោះនេះដែរ ហើយពុំមានតុលាការអន្តរជាតិណាមួយកាត់សេចក្តីថា កោះត្រល់នេះជារបស់វៀតណាម បិទផ្លូវតវ៉ាដូចនេះឡើយ។ សន្ធិសញ្ញាឆ្នាំ១៩៨២ រវាងវៀតណាមនិងសាធារណរដ្ឋប្រជាមានិតុកម្ពុជា និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ តើមានឥទ្ធិពលមកលើកោះនេះឬទេ ? សូមបងប្អូនរួមជាតិពិចារណា ! ។៚

❑